**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៦ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្ត លើនាវាបរទេសដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញសេចក្តីសម្រេចលេខ ៦៤ សសរ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ស្តីពីការបញ្ចប់កិច្ចសន្យារវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន COSMOS GROUP
- បានឃើញសេចក្តីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ស្តីពីការប្រគល់ភារកិច្ចជូនក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យបន្តការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតគណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជារហូតដល់បញ្ចប់សុពលភាពនៃវិញ្ញាបនបត្រ ព្រមទាំងទទួលដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលអាចកើតមានជាយថាហេតុបន្ទាប់ពីការបញ្ចប់កិច្ចសន្យា ដែលមានសមាសភាព ដូចខាងក្រោម ៖

១- ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន

២- ឯកឧត្តម **សុខុម តេជទន្តមុនី** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានអចិន្ត្រៃយ៍

៣- ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម **ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦- ឯកឧត្តមនាយឧត្តមសេនីយ៍ **ឆាង ទៅ** ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ សមាជិក ។

**ប្រការ២ .—**

គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជារហូតដល់បញ្ចប់សុពលភាពនៃវិញ្ញាបនបត្រ ព្រមទាំងទទួលដោះស្រាយនូវរាល់បញ្ហាទាំងឡាយ ដែលអាចកើតមានជាយថាហេតុបន្ទាប់ពីការបញ្ចប់កិច្ចសន្យា មានភារកិច្ចដូចខាងក្រោម ៖

- គ្រប់គ្រងបន្ត ចំនួននាវាបរទេសដែលដោតទង់ជាតិកម្ពុជា និងដោះស្រាយបញ្ចប់
- ត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាពនាវា ដែលកំពុងធ្វើនាវាចរណ៍លើផ្ទៃសមុទ្រ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញា កិច្ចព្រមព្រៀង ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការដឹកជញ្ជូន តាមផ្លូវសមុទ្រ
- រៀបចំប្រមូល ចងក្រង និងរក្សាទុកនូវឯកសារ ព័ត៌មានជាលាយលក្ខណ៍អក្សរផ្សេងៗពាក់ព័ន្ធនឹងដំណើរការសកម្មភាពរបស់គណៈកម្មការ
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**ប្រការ៣ .—**

អនុប្រធាន និងសមាជិក នៃគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានមានធុរៈ ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស ។

ប្រធានគណៈកម្មការអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ផ្នែកឯកជន ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីពិគ្រោះយោបល់អំពីការងារជាក់លាក់ណាមួយ ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងការចុះបញ្ជីនាវាបរទេសដោតទង់ជាតិកម្ពុជា ។

គណៈកម្មការមានសិទ្ធិប្រើត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៤ .—**

គណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលបានការចុះបញ្ជីដោតទង់ជាតិកម្ពុជា មានលេខាធិការដ្ឋានមួយ ជាសេនាធិការ នៅក្រសួងសាធារណការនិងដឹកជញ្ជូន ។

លេខាធិការដ្ឋានរបស់គណៈកម្មការជំនាញ ដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

**ប្រការ៥ .—**

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេស ដែលទទួលការចុះបញ្ជីដោតទង់ជាតិកម្ពុជា ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។

គណៈកម្មការជំនាញដើម្បីគ្រប់គ្រងបន្តលើនាវាបរទេសដែលទទួលការចុះបញ្ជីដោតទង់ជាតិកម្ពុជា មានសិទ្ធិទទួលចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៦ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__*កន្លែងទទួល*__ :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*